សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ
និងពេញសមត្ថភាព របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
១១ ធ្នូ ២០១៥

- **សូមគោរព លោកវេជ្ជបណ្ឌិត កែវ សាងផលបុណ្យ ប្រធានស្រុកប្រតិបត្តិបាកានខេត្តពោធិ៍សាត់**
- **សូមគោរព លោកវេជ្ជបណ្ឌិត ហ៊ីង សាមិត្ត ប្រធានស្រុកប្រតិបត្តិព្រៃកប្បាសខេត្តតាកែវ**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិចំនួនពីររួមមាន "គម្រោងបំពាក់ឧបករណ៍បរិក្ខារពេទ្យនៅមន្ទីរពេទ្យបង្អែកបាកានខេត្តពោធិ៍សាត់" និង"គម្រោងសាងសង់អគារវះកាត់នៅមន្ទីរពេទ្យបង្អែកព្រៃកប្បាស ខេត្តតាកែវ"។

គម្រោងទាំងពីរ ដែលយើងតែបានចុះហត្ថលេខានៅថ្ងៃនេះ មានគោលដៅដើម្បីផ្តល់សេវាសុខភាពប្រកបដោយគុណភាពជូនដល់ប្រជាពលរដ្ឋនៅមូលដ្ឋាននៃគម្រោងនិមួយៗ។ យើងទទួលស្គាល់ថា វិស័យសុខាភិបាល គឺជាវិស័យអាទិភាពសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ហើយយើងក៏ជឿជាក់យ៉ាងមុតមាំថា ការកែលម្អវិស័យសុខាភិបាលនេះ គឺជាគន្លឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ក៏ដូចជាការពង្រឹងនូវសុខមាលភាពសម្រាប់ប្រជាជនកម្ពុជាផងដែរ។ ខ្ញុំសង្ឃឹមថា ការគាំទ្ររបស់ជប៉ុន នឹងរួមចំណែកយ៉ាងធំធេងដល់គោលបំណងទាំងនេះ។

គម្រោងទីមួយ មានថវិកាសរុប ៨៣,០៨០ ដុល្លារអាមេរិក គឺដើម្បីបំពាក់ឧបករណ៍បរិក្ខារពេទ្យចំនួន៥ ផ្តល់ជូនដល់មន្ទីរពេទ្យបង្អែកបាកាន ក្នុងខេត្តពោធិ៍សាត់។ យើងរំពឹងថាគម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ប្រមាណជា១៦០,០០០នាក់ អោយទទួលបាននូវសេវាសុខភាពប្រកបដោយគុណភាពល្អប្រសើរជាងមុន ។

គម្រោងទីពីរ មានថវិកាសរុប ៩០,៣៣៣ ដុល្លារអាមេរិក គឺដើម្បីសាងសង់អគារវះកាត់ក្នុងមន្ទីរពេទ្យបង្អែកព្រៃកប្បាស ក្នុងខេត្តតាកែវ។ គម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋប្រមាណជា ១៦០,០០០នាក់ អោយទទួលបាននូវសេវាសុខភាពប្រកបដោយគុណភាពល្អប្រសើរជាងមុនផងដែរ ។

រដ្ឋាភិបាលជប៉ុន បាននឹងកំពុងបន្តផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការគាំទ្រដល់គម្រោងអភិវឌ្ឍជាច្រើន។ រដ្ឋាភិបាលជប៉ុន ក៏បាននឹងកំពុងជួយដល់ប្រទេសកម្ពុជាក្នុងវិស័យនេះយ៉ាងសកម្មផងដែរ តាមរយៈការសាងសង់អគារជម្ងឺទូទៅ និងគ្លីនិក ព្រមទាំងការផ្តល់នូវការបណ្តុះបណ្តាល

នានាជាច្រើន។

ខ្ញុំសង្ឃឹមថា គម្រោងទាំងពីរនេះ នឹងត្រូវបានអនុវត្តទៅយ៉ាងរលូន ហើយនឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ បន្ទាប់ពីបញ្ចប់គម្រោង ដើម្បីអោយប្រជាជនកាន់តែច្រើន ទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានស្រាប់រួចមកហើយរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

**សូមអរគុណ!**